# កម្រងឯកសារ វិនិយោគវិស័យ ជ្រូក




## ខែមករា ២០១១





# កម្រងឯកសារវិនិយោគវិស័យជ្រូក


មាតិការអត្ថបទ.......................................................១

មតិស្វាគមន៍របស់ USAID.........................................២

ចំនុចខ្លាំងថ្នាក់ជាតិ ......................................................................៣

ការបើកចំហចំពោះអាជីវកម្ម

កំលាំងពលកម្មមានផលិតភាពខ្ពស់និងមានតម្លៃទាប

ទីតាំងយុទ្ធសាស្ត្រក្នុងតំបន់

ហេតុផលដើម្បីវិនិយោគទុនវិស័យចិញ្ចឹមជ្រូកនៅកម្ពុជា.......................៥

១. សេចក្តីផ្តើម

២. ធនធាន

៣. ស្ថានភាពទីផ្សារ

៤. បរិយាកាសអាជីវកម្ម

៥. ការធ្វើពាណិជកម្ម

៦. ការគាំទ្រផ្នែកដ្ឋារចនាសម្ព័ន្ធ

តើអ្នកចង់ស្វែងយល់បន្ថែមទៀតទេ? ............................................១៥



## មតិស្វាគមន៍របស់ USAID

USAID មានសេចក្តីសោមនស្សរីករាយសូម បង្ហាញ ជូនពី កម្រងឯកសារវិនិយោគ ស្តីពីឧស្សាហកម្មជ្រូកនៅកម្ពុជា ។

ជាទូទៅទីផ្សារគ្មានដែនកំណត់ទេដែលធ្វើឲយើងពិបាកទទួលបានព័ត៌មានទាក់ទងនឹងការវិនិយោគ ។ ដូច្នេះ គោលបំណងនៃកម្រងឯកសារនេះដើម្បី ជួយជាគំនិតខ្លះៗ និងផ្តល់នូវចំណុចចាប់ផ្តើមដែលអ្នកអាច យកទៅសិក្សាឲកាន់តែស៊ីជំរៅបន្ថែមទៀត ។

ឯកសារនេះផ្តល់ឲអ្នកជាទិដ្ឋភាពទូទៅដែលអាចសមស្របទៅនឹងវិស័យចិញ្ចឹមជ្រូក និងអាចឲអ្នកកំណត់បាននូវ គន្លឹះសំខាន់ៗ ដែលនឹងរួមចំណែកដល់ការ វិនិយោគប្រកបដោយសុវត្ថិភាពកាន់តែទូលំទូលាយ ។ បញ្ហាទាំងនេះនឹងត្រូវដោះស្រាយ ដូចដែលមានភ្ជាប់មកជាមួយ

*តើកម្ពុជាមានធនធាន និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ អ្វីខ្លះដើម្បីគាំទ្រដល់ការប្រកួតប្រជែងឧស្សាហកម្មជ្រូកដែរឬទេ?*

*តើបរិមាណការផលិតនៃឧស្សាហកម្មជ្រូកបច្ចុប្បន្នបានកំរិតណា និង តើវាបំពេញទៅនឹងតម្រូវការក្នុងស្រុក និងក្រៅស្រុកបានដែរឬទេ?*

*តើរាជរដ្ឋាភិបាលមានទស្សន:បែបណា ហើយអ្នករំពឹងទុក ថានឹងទទួលបានការគាំទ្រអ្វីខ្លះ?*




*តើមានស្ថាប័នសកម្មណាខ្លះដែលពាក់ព័ន្ធនៅក្នុងឧស្សាហកម្មចិញ្ចឹមជ្រូក? តើអ្នកណាដែលអាចផ្តល់ព័ត៌មានបន្ថែមដល់អ្នក??*

*តើឪកាសវិនិយោគឧស្សាហកម្មចិញ្ចឹមជ្រូកសំខាន់ៗមាននៅតំបន់ណាខ្លះ?*

កម្ពុជាជាប្រទេសដែលមានសេដ្ឋកិច្ចរស់រវើកដែលទទួលបាននូវការកោតសរសើរយ៉ាងខ្លាំងចំពោះគោលនយោបាយវិនិយោគប្រកបដោយការប្រកួតប្រជែងបែបមិត្តភាព ។ កម្ពុជាបានបង្ហាញខ្លួនឯងផងដែរនូវសេដ្ឋកិច្ចរឹងមាំដែលបានងើបឡើងយ៉ាងឆាប់រហ័សពីវិបត្តិហិរញ្ញវត្ថុពិភពលោក ។ ធនាគារ ADB និង IMF ទាំងពីរបានលើកកម្ពស់ការព្យាករណ៍ពីកំណើន GDP សំរាប់កម្ពុជា ឆ្នាំ ២០១០ ដែលបង្ហាញពីដំណើរសេដ្ឋកិច្ចរឹងមាំ ។ ទន្ទឹមនោះ កម្ពុជាបានទទួលកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនៅក្នុងមួយទសវត្សរ៍កន្លងមកនេះ ហើយវា នៅតែមានឪកាសវិនិយោគជាច្រើនទៀតសំរាប់វិនិយោគិនជាសហគ្រិន ។ យើងសង្ឃឹមថា កម្រងឯកសារវិនិយោគនេះ នឹងជំរុញកាន់តែខ្លាំងក្លាថែមទៀតដល់អ្នកដែលមានបំណងចង់វិនិយោគក្នុងឧស្សាហកម្មចិញ្ចឹមជ្រូក ហើយ សូមជូនពរដល់អស់ លោក លោកស្រី និងអាជីវកម្មរបស់លោក លោកស្រីឲ្យទទួលបានជោគជ័យគ្រប់ពេលវេលា ។

សូមទទួលនូវការគោរពរាប់អានពី គម្រោង

MSME Project, USAID ។



## ចំណុចខ្លាំងថ្នាក់ជាតិ

អស់រយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ កម្ពុជាបានលេចមុខមាត់ថាជាប្រទេសមួយដែលមានសេដ្ឋកិច្ចរស់រវើកនិងរឹងមាំនៅក្នុងតំបន់ ហើយបានចូលរួមចែករំលែកពីកត្តាចាំបាច់ដែលមានសំខាន់ជាច្រើនសំរាប់ការអភិវឌ្ឍន៍អាជីវកម្មប្រកបដោយជោគជ័យ និងមានការរីកចំរើន។

### ការបើកចំហចំពោះអាជីវកម្ម

- ✓ ពន្ធអាជីវកម្មទាប- ពន្ធ២០%លើផលចំណេញអាជីវកម្ម (អាចអនុគ្រោះពន្ធរហូតដល់៥ឆ្នាំ ចំពោះការខាតបង់) ។
- ✓ គ្មានការដាក់កំហិតលើម្ចាស់កម្មសិទ្ធិជាជនបរទេស ។
- ✓ ចំណាត់ថ្នាក់នាំមុខប្រទេសចិន ឥណ្ឌា វៀតណាមនិងឥណ្ឌូនេស៊ីខាងសេរីភាពសេដ្ឋកិច្ច[១]។
- ✓ ផ្តល់ភាពស្មើគ្នាចំពោះអ្នកវិនិយោគទាំងអស់ ។
- ✓ នាំមុខប្រទេសហ្វីលីពីន ចិន និងវៀតណាមខាងផ្នែកការការពារអ្នកវិនិយោគ[២] ។
- ✓ គ្មានការត្រួតពិនិត្យតម្លៃលើទំនិញឬសេវាកម្ម ។
- ✓ គ្មានការត្រួតពិនិត្យលើការប្តូររូបិយវត្ថុបរទេសឬ គ្មានការដាក់កំហិតលើការប្តូរប្រាក់ ។



*"ដូចជាប្រទេសចិន និងឥណ្ឌា នៅក្នុងសម័យ កាលមុនៗដែរ កម្ពុជាត្រូវបានគេចាត់ទុក ជា កន្លែងដែលមានសក្តានុពលភាព សម្រាប់ ការវិនិយោគខាងរោងចក្រដែលទទួលបានជោគជ័យនៅពេលខាងមុខ ជាពិសេសដោយ សារតែពលកម្មតម្លៃទាប ហើយប្រាក់តំកល់សម្រាប់ទូទាត់ពេលមានហានិ ភ័យមានកំរិតទាប...ម្យ៉ាងទៀតកម្ពុជាទទួលបានអត្ថប្រយោជន៍ដោយនៅជិតនឹងឆ្នេរ ខាងលិចនៃសហរដ្ឋអាមេរិក" ។*

*-Price Waterhouse Coopers*

- ✓ គ្មានការដាក់កំហិតលើការបង្វិលដើមទុនទៅប្រទេសវិនិយោគិនវិញ ។
- ✓ ជាប្រទេសដំបូងគេក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍(LDCs) ដែលបានចូលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក ។
- ✓ គ្មានការដាក់កំហិតលើបរិមាណពាណិជ្ជកម្មដើម្បីកាត់បន្ថយរបាំងពន្ធគយ ។



កម្ពុជាទទួលបានការ អនុគ្រោះពន្ធ និងកូតាទៅកាន់ទីផ្សារធំៗរបស់ពិភពលោក (ដូចជា អាមេរិក អឺរ៉ុប ជប៉ុន និងប្រទេសជាសមាជិកអាស៊ានជាច្រើនទៀត) ។

✓ អាជ្ញាធរខេត្តមានសិទ្ធិអំណាចក្នុងការអនុម័តការវិនិយោគក្រោមទឹកប្រាក់២លានដុល្លារ ដើម្បីជំរុញការចាប់ផ្តើមអភិវឌ្ឍន៍អាជីវកម្មឲ្យបានឆាប់រហ័ស ។

*"កម្ពុជាកំពុងបើកចំហយ៉ាងទូលំទូលាយចំពោះអាជីវកម្ម ហើយរាជរដ្ឋាភិបាលកម្ពុជានឹងខិតខំព្យាយាមចអស់ពីសមត្ថភាពដើម្បីធានាបាននូវបរិយាកាសអនុគ្រោះ និងភាពជោគជ័យគ្រប់សហគ្រាសទាំងអស់នៅកម្ពុជា"* នេះជាប្រសាសន៍សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

## កំលាំងពលកម្មមានផលិតភាពខ្ពស់ និងមានតម្លៃទាប

បើប្រៀបធៀបទៅនឹងប្រទេសជាច្រើន នៅក្នុងតំបន់ ប្រទេសកម្ពុជាមានសក្តានុភាពក្នុងការប្រកួតប្រជែងពីអត្រាតម្លៃកំលាំងពលកម្ម ហើយកម្លាំងពលកម្មមាន ផលិតភាពខ្ពស់ដែលធ្វើឲ្យកម្ពុជាក្លាយជាទិសដៅដ៏ ទាក់ទាញសម្រាប់ឧស្សាហកម្ម ដែលប្រើប្រាស់ កម្លាំងពលកម្មច្រើន ។

កាលពីប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ កម្ពុជាមានកម្លាំងពលកម្មកើនឡើងជាង៥០% ហើយចំនួននេះច្រើនជាងទ្វេរ ដងនៅក្នុងប្រទេសផ្សេងៗនៅតំបន់អាស៊ី[៣]។ មិនតែប៉ុណ្ណោះកម្ពុជាមានប្រជាពលរដ្ឋវ័យក្មេងច្រើន(ប្រជាពល រដ្ឋពាក់កណ្តាលមានអាយុក្រោម២០ឆ្នាំ)ហើយកម្លាំង ពលកម្មនេះនឹងបន្តកើនឡើងជាបន្តទៀត ។

*"អ្នកមានទីក្រុងធំៗបំផុតពីរ នៅអាស៊ីអមសងខាងអ្នក ។ អ្នកមានប្រជាជន១៥លាននាក់នៅទីក្រុងបាងកក និង៨លាននាក់នៅទីក្រុង ហូជី មិញ ហើយចំនួននេះកំពុងតែមានការកើនឡើងក្នុងទីក្រុងទាំងពីរ"* ។ Edward Hopkins, CB Richard Ellis Group Inc.

## ទីតាំងយុទ្ធសាស្រ្តក្នុងតំបន់

កម្ពុជាមានទីតាំងល្អឥតខ្ចោះ ដែលនៅចំតំបន់សំបូរថាមពលជាងគេបំផុតនៅក្នុង ពិភពលោក។ ដោយស្ថិតនៅជាប់ប្រទេសថៃ និង វៀតណាម កម្ពុជា គឺជាផ្នែកមួយនៃមហាអនុតំបន់ទន្លេមេគង្គ សេដ្ឋកិច្ចខាងត្បូងដែលលាតសន្ធឹងពី ទីក្រុងហូជីមិញ ដល់ក្រុងបាងកក ។

ដោយសារតែទីតាំងយុទ្ធសាស្រ្តបែបនេះ កម្ពុជាទទួលបានការគាំទ្រពីអន្តរជាតិគួរឲ្យកត់សំគាល់នៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរបស់ខ្លួន ដើម្បីជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មនៅក្នុងប្រទេស និងជាមួយប្រទេសជិតខាង ។ ជាលទ្ធផលការ ធ្វើពាណិជ្ជកម្មជាមួយនឹងប្រទេសវៀតណាម និងថៃកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ។

 

# ហេតុផលវិនិយោគទុនលើការចិញ្ចឹមជ្រូកកម្ពុជា

### ១.សេចក្ដីផ្ដើម

សាច់ជ្រូកជាអាហារសំខាន់របស់ប្រជាជនកម្ពុជា ដោយការបរិភោគជាមធ្យមកើនឡើងជា រៀង រាល់ឆ្នាំ ពី ១៩៩៩ដល់២០០៧ ការ បរិភោគ ប្រចាំឆ្នាំ ជាមធ្យម គឺ ៩,២៩គក ក្នុង មួយនាក់[៤] ។ តែទោះ ជាយ៉ាងណាក៏ដោយ ផលិតកម្មក្នុងស្រុក មិនអាច បំពេញតម្រូវការ បានគ្រប់គ្រាន់ទេ ដោយសារតែការ ចិញ្ចឹម ទទួលបានផលតិច ពី ព្រោះការចិញ្ចឹមភាគច្រើន ជាលក្ខណៈគ្រួសារ។ ដូចនេះ ដើម្បីបំពេញ សេចក្ដីត្រូវការខាងលើ តំរូវឲមានការនាំចូល បរិមាណច្រើនពីប្រទេស ជិតខាងរួមមានប្រទេសថៃ និងវៀតណាមដែល ជាប្រទេសចិញ្ចឹមជ្រូកច្រើន និងទទួលបាន ផលិតកម្មខ្ពស់គ្របដណ្ដប់នៅក្នុងតំបន់។ ដោយយោងទៅលើផលិតកម្មមិនគ្រប់គ្រាន់នា

ពេលបច្ចុប្បន្ន វាជាឱកាសល្អសំរាប់វិនិយោគ ដោយ ប្រើបច្ចេកទេសទំនើបៗដើម្បីទាញយក ផល ចំណេញពីការកើនឡើងតំរូវការសាច់នៅ ក្នុងស្រុកនិងតំបន់។

## ២. ធនធាន

ប្រទេសកម្ពុជាមានអំណោយផលដោយមានកត្តា ចាំបាច់ហើយសំខាន់ៗជាច្រើនសំរាប់ជួយគាំទ្រ ដល់ ឧស្សាហកម្មចិញ្ចឹមជ្រូកឲទទួលបានជោគ ជ័យព្រោះមានដីគ្រប់គ្រាន់មានវត្ថុធាតុដើមសំរាប់ ផលិតចំណី និងកម្លាំងពលកម្មមានតម្លៃទាប ។

## ដីធ្លី

កម្ពុជាមានផ្ទៃដីទូលំទូលាយសំរាប់និរន្តភាពការ ចិញ្ចឹមជ្រូក និងផលិតចំណី[៥] ។ កម្ពុជាមានផ្ទៃដី គ្របដណ្ដប់១៨,១លានហិកតា ដែលមានដង់ ស៊ីតេ ប្រជាជនរស់នៅត្រឹមតែ ៧៥នាក់ ក្នុងមួយ គម[២] ។ ដូចនេះ ធនាគារពិភពលោកបានប៉ាន់ ប្រមាណថា ដីប្រហែល ១០លាន ហ.ត អាច ប្រើសំរាប់សកម្មភាពលើកកម្ពស់សេដ្ឋកិច្ច ជា ពិសេសលើវិស័យកសិកម្ម[៦] ។

ជាងនេះទៅទៀតវត្ថុធាតុដើមដែលមានស្រាប់គឺ មានសារសំខាន់សំរាប់ការចិញ្ចឹមជ្រូក ។ជាទូទៅ ថ្លៃផលិតកម្មសរុប៧០%ចំណាយ[៧]ទៅលើចំណី។ តែចំពោះការចិញ្ចឹមបែបលក្ខណៈគ្រួសារ ចំណា-យនេះអាចកើនឡើងប្រមាណ៨០ភាគរយ ។ថ្លៃ ជាធម្មតា កម្ពុជាផលិតវត្ថុធាតុដើមលើសពី សេចក្ដីត្រូវការសំរាប់ការផលិតចំណីសត្វ។ តែ ទោះជាយ៉ាងណាក៏ កាលពីប៉ុន្មានទសវត្សរ៍កន្លង ទៅនេះ កម្ពុជាបាននាំចេញនូវវត្ថុធាតុដើមទាំង នេះជាជាងការកែច្នៃនៅក្នុងប្រទេស ។ នៅឆ្នាំ ២០០៨ កម្ពុជាបាននាំចេញសណ្ដែកសៀង ៨១.000តោន និង ពោត ៣៧៤.០០០តោន



ស្មើនឹង ៧៥% និង៦១%នៃ ផលសរុបរបស់ផលិតផលនីមួយៗ[៩] ។

ភាគរយគ្រាប់ធញ្ញជាតិដែលនាំចេញនិងលក់ក្នុងស្រុក[១០]




ការដាំដុះដំណាំគឺជាគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចដ៏សំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលរដ្ឋាភិបាល បានជួយសម្របសម្រួលយ៉ាងសកម្មតាមរយៈការផ្តល់ដីសម្បទាន និងការលើកទឹកចិត្តដល់ការវិនិយោគទុនផ្សេងៗ ។

## កម្លាំងពលកម្ម

កម្ពុជា គឺមិនត្រឹមតែជាទីតាំងដែលទទួលស្គាល់ជាអន្តរជាតិថាសំបូរកម្លាំងពលកម្មប៉ុណ្ណោះទេ តែថែមទាំងមានប្រជាជន ដែលយល់ដឹងពីការ



ចិញ្ចឹមជ្រូកទៀតផង។ ប្រជាជនខ្មែរជាច្រើននៅពេលបច្ចុប្បន្នចិញ្ចឹមជ្រូក និងអ្នកភូមិជាច្រើនបានទទួលសេវាបសុពេទ្យ និងការផ្សព្វផ្សាយ បច្ចេកទេសចិញ្ចឹម ដែលផ្តល់ដោយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ។ ដូចនេះ ពួកគេមានជំនាញ ទូលំទូលាយដែលជាមូលដ្ឋានគ្រឹះត្រូវពង្រឹងបន្ថែម ។

## ៣. ស្ថានភាពទីផ្សារ

ស្ថានភាពទីផ្សារអនុគ្រោះដល់ការវិនិយោគលើខ្សែសង្វាក់អាជីវកម្មជ្រូក ព្រោះមានតម្រូវការក្នុងស្រុក និងក្នុងតំបន់ច្រើន ។

**តម្រូវការ** នៅអាស៊ីអាគ្នេយ៍តំរូវការសាច់ជ្រូកមាន៥៨%នៃបរិមាណសាច់ ដែលគេបរិភោគសរុប ។ការចូល ចិត្តសាច់ជ្រូក បាន គាំទ្រយ៉ាងខ្លាំងដល់ឧស្សាហកម្ម ចិញ្ចឹមជ្រូកនៅប្រទេសអាស៊ីអាគ្នេយ៍ ។

នៅកម្ពុជា ការបរិភោគសាច់ក្នុងមួយនាក់បានកើនឡើងជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ ១៩៩៨ នៅពេលដែលមានការកើនឡើងប្រាក់ចំណូល[១១] ក្នុងម្នាក់ៗ។ ទោះបី មានកំណើនកើនឡើងបែបនេះក៏ដោយ ការបរិភោគសាច់ជ្រូកនៅកម្ពុជា នៅតែទាបជាងប្រទេសជិតខាង។ដូចនេះជាយោបល់គួរបង្កើនទីផ្សារសាច់ជ្រូកបន្ថែមទៀត ។

## ការប្រៀបធៀបការបរិភោគសាច់ជ្រូកក្នុងម្នាក់ (២០០៧)[១២]




ចាប់ពីឆ្នាំ២០០៨ ប្រាក់ចំណូលប្រជាជនកម្ពុជាម្នាក់ៗបានកើនឡើងអត្រា ៦,៩% ក្នុងមួយឆ្នាំ អំឡុងរយៈពេល៥ឆ្នាំមុន[១៣] ។ ការបរិភោគសាច់ជ្រូកសរុបសង្ឃឹមថា នឹងបន្តកើនឡើងស្មើនឹងអត្រាកំណើន១,៥៩%នៃប្រជា-ជនកម្ពុជាទាំងមូល ។

នាពេលបច្ចុប្បន្ននេះ តាមការប៉ាន់ស្មានការបរិភោគសរុប ចន្លោះពី១,៥លាន[១៤]និង២លានក្បាល[១៥]ក្នុងមួយឆ្នាំ ។ ចំនួននេះ ប្រហែលជាមួយភាគបីនៃអ្នកបរិភោគសាច់គឺរស់នៅទីក្រុងភ្នំពេញ ដែលជារាជធានីប្រទេសកម្ពុជា និងជាទីផ្សារធំជាងគេ ក្នុងស្រុក ។ ក្រាហ្វិកខាងក្រោមនេះ បង្ហាញ ពីសមាមាត្រ និងការ ប្រៀបធៀបជាមួយនឹង ចំនួនប្រជាជននៅទីក្រុងភ្នំពេញ ដែលបង្ហាញពី អត្រា កំនើនការបរិភោគសាច់ច្រើននៅរាជធានី ។

## ការប្រៀបធៀបការបរិភោគសាច់ជ្រូកនៅតាមខេត្ត និងទីក្រុងភ្នំពេញ




ការស្រាវជ្រាវបានបង្ហាញថា អ្នកបរិភោគនៅទីក្រុង ភ្នំពេញចូលចិត្តបរិភោគសាច់សុទ្ធដែលបានមកពីពូជជ្រូកនាំចូល ហើយសាច់មានខ្លាញ់ច្រើនបានមកពីពូជជ្រូកក្នុងស្រុក។

## ការរួមចំណែកនៃការចិញ្ចឹមជាលក្ខណៈគ្រួសារ ដល់ ឧស្សាហកម្មសរុប (2006)[18]




## ឧបសគ្គនៃការផ្គត់ផ្គង់



ទោះបីជាមានតម្រូវការខ្ពស់នៅអាស៊ីអាគ្នេយ៍ និងតម្រូវការកើនឡើងនៅកម្ពុជាយ៉ាងណាក៏ដោយ ក៏ឧស្សាហកម្មជ្រូកក្នុងស្រុកមិនអាចបំពេញសេចក្តីត្រូវការក្នុងស្រុក ឬឆ្លើយតបទៅនឹងកំរិតស្តង់ដាសំរាប់នាំចេញបានទេ ។

ការផ្គត់ផ្គង់ក្នុងស្រុកភាគច្រើនបានមកពីការចិញ្ចឹមតាមបែបលក្ខណៈគ្រួសារដែលជាធម្មតាចិញ្ចឹមជ្រូកតិចជាងពីរក្បាល ប៉ុន្តែមានចំនួន៩0% នៃការចិញ្ចឹមសរុបទាំងមូល[១៧] ។ តាមតារាងខាងក្រោមបាន បង្ហាញថាការចិញ្ចឹមបែបនេះមានចំនួនច្រើនជាងប្រទេសជិតខាង គឺវៀតណាម ឬថៃ ។

ដូច្នេះ បញ្ហាឧស្សាហកម្មចិញ្ចឹមជ្រូកនៅកម្ពុជា គឺទាក់ទងទៅនឹងអ្នកចិញ្ចឹមជាលក្ខណៈគ្រួសារមានចំនួនច្រើន។ម្យ៉ាងទៀត ខ្សែសង្វាក់ផ្គត់ផ្គង់សាច់ជ្រូកមិនមានជាប់លាប់ហើយមានតែអ្នកផ្គត់ផ្គង់២ទៅ៣នាក់ប៉ុណ្ណោះបានផ្គត់ផ្គង់ជាប្រចាំ ដើម្បីទទួលបាននិរន្តភាពខាងផ្នែកសេដ្ឋកិច្ចរបស់ពួកគេ។ កង្វះខាតទាំងនេះដោយសារអ្នកចិញ្ចឹមតាមបែបលក្ខណៈគ្រួសារមិនបានទទួលសេវា

ផលិតផលដែលមានគុណភាពល្អ ដូចជា ចំណីជ្រូក ថ្នាំសត្វ និងពូជជាដើម។ ដូច្នេះ ជ្រូកទទួលរងអត្រាងាប់ខ្ពស់ វដ្តនៃការចិញ្ចឹមជ្រូកសាច់មានរយៈពេលវែង មានទំងន់ស្រាល និងស៊ីចំណីអស់ច្រើនជាងអ្នកចិញ្ចឹមជ្រូកបែបឧស្សាហ-កម្ម ។ក្រាហ្វិកខាងក្រោមនេះបង្ហាញពីលទ្ធផលនៃការបៀបធៀបរវាងអ្នកចិញ្ចឹមជ្រូក របស់ប្រជា-ជន កម្ពុជាជាលក្ខណៈគ្រួសារ ជាមួយ និងអ្នកចិញ្ចឹមខ្នាតធំ[១៩] ។



**ការប្រៀបធៀបរវាងការចិញ្ចឹមជាលក្ខណៈគ្រួសារ និងអ្នកចិញ្ចឹមជា   អាជីវកម្មទ្រង់ទ្រាយធំនៅកម្ពុជា (២00៦)[២0]**

| | អ្នកចិញ្ចឹមជ្រូក | |
|---|---|---|
| | ខ្នាតតូច | ខ្នាតធំ |
| បរិមាណស៊ីចំណីជាមធ្យម (គក) | 7.25 | 2.8 |
| ទំងន់ពេលសំលាប់ជាមធ្យម(គក) | 65 | 94 |

បញ្ហាសំខាន់នោះ គឺថាពាណិជ្ជកម្មជាច្រើនត្រឹមកំរិតថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ។ ជ្រូករបស់អ្នកចិញ្ចឹមបែបលក្ខណៈគ្រួសារលក់ទៅឲ្យឈ្មួញកណ្តាល ហើយបន្ទាប់មកគេយកទៅកាប់នៅកន្លែងសត្តឃាតក្នុងស្រុកដែលមានច្បាប់អនុ-ញ្ញាត ឬគ្មានច្បាប់ ។ បន្ទាប់មក គេដាក់លក់សាច់ទាំងនោះនៅតាមភូមិ ស្រុក តូបកណ្តាលវាល និងទីផ្សារ ។ កាដាក់លក់បែបនេះមិនមានការត្រួតពិនិត្យគុណភាព ការតាមដាន និង ការដឹកជញ្ជូន និងរក្សាទុក សាច់មិនបានល្អ ។ អ្នកចិញ្ចឹមជ្រូកខ្នាតធំដែលនៅក្នុងស្រុកមួយចំនួនទទួលបានលទ្ធផលល្អប្រសើរគួរឲ្យកត់សំគាល់ ដែលអាចការប្រកួតប្រជែងជាមួយនឹងអ្នកចិញ្ចឹមនៃប្រទេសជិតខាងបាន ។

**ការប្រៀបធៀបអាជីវករចិញ្ចឹមជ្រូកខ្នាតធំ(២00៦)**

| | អាជីវករចិញ្ចឹមជ្រូកខ្នាតធំ | | |
|---|---|---|---|
| | កម្ពុជា | វៀតណាម | ថៃ |
| បរិមាណស៊ីចំណីជាមធ្យម (គក) | 2.8 | 2.6 | 2.6 |
| ទំងន់ពេលសំលាប់ជាមធ្យម(គក) | 94 | 94 | 110 |

តែទោះជាយ៉ាងណាក៏ដោយ អាជីវករចិញ្ចឹមជ្រូកខ្នាតធំទាំងនេះមិនទាន់ផលិតបានគ្រប់គ្រាន់

នៅឡើយទេ ហើយជាលទ្ធផល ផលិតកម្មក្នុងស្រុកទូទាំងប្រទេសនៅមានឧបសគ្គធ្ងន់ធ្ងរ ។ ដូច្នេះ អស់រយៈពេលជាច្រើនឆ្នាំ វាចាំបាច់ត្រូវនាំចូលជ្រូកពីប្រទេសជិតខាង ថៃ និងវៀតណាម ។ វាមានប្រពន្ធ័កូតារបស់រាជរដ្ឋាភិបាលត្រូវធ្វើច្បាប់សំរាប់ការផ្គត់ផ្គង់ និងការការពារទីផ្សារផលិតផលក្នុងស្រុក ។

នៅពេលមានឧប្បត្តិហេតុផ្ទុះជម្ងឺក្នុងប្រទេសដែលនាំជ្រូកចេញមកកម្ពុជា ការនាំចូលមានចំនួនច្រើនយ៉ាងសន្ធឹកសន្ធាប់។នៅក្នុងអំឡុងពេលនេះ អាជីវករថៃ និងវៀត ណាមបានឃើញច្រកសំរាប់ទីផ្សារនាំចេញ ហើយទន្ទឹមនឹងនេះ កម្ពុជានៅតែជាទីផ្សារដែលងាយស្រួលនាំចេញនូវផលិតផលដ៏ច្រើនលើសលប់ ។

ការស្រាវជ្រាវពីការផ្ទុះជំងឺនៅឆ្នាំ២០០៦[២១] បានបង្ហាញថា ជំងឺទាំងនេះបានបណ្តាលឲតំលៃសាច់ជ្រូកធ្លាក់ចុះយ៉ាងខ្លាំង ហើយការនាំចូល យ៉ាងច្រើនគ្មានច្បាប់ធ្វើឲ្យថយចុះអ្នកផ្គត់ផ្គង់ក្នុងស្រុក។ តែទោះបីយ៉ាងណាក៏ដោយ របាយការណ៍ក៏បានបង្ហាញថា ប្រតិកម្មរបស់រាជរដ្ឋា-ភិបាលមានប្រសិទ្ធភាពយ៉ាងខ្លាំងនៅក្នុងការ កាត់បន្ថយការនាំចូលគ្មានច្បាប់អនុញ្ញាតឲ្យចុះ ដល់ចំនួនតិចបំផុត។ ជាងនេះទៅទៀត ការខូច ខាតផលិតកម្មជ្រូកបានផ្តល់ផលចំណេញ ដល់អ្នកបរិភោគ និងអ្នកកែច្នៃសាច់ជ្រូកដោយទទួលបានតម្លៃសាច់ជ្រូកថោក ។

នៅអំឡុងឆ្នាំ២០១០ ការផ្ទុះជំងឺត្រចៀកខៀវ (PRRS)នៅវៀតណាម រដ្ឋាភិបាលបានចាត់វិធានការជាបន្ទាន់ និងបានហាមឃាត់ការនាំចូលទាំងអស់នៅថ្ងៃទី ១ សីហា ២០១០ពីប្រទេសទាំងពីរ ថៃ និងវៀតណាម ។តាមរយៈការពិនិត្យមើលពីតម្លៃសាច់ជ្រូកលក់ដុំនៅក្នុងកំឡុង ពេលនោះ បង្ហាញថា តម្លៃមានស្ថេរភាព[២២] តែជំនឿថា តំលៃសាច់នឹងមានការប្រែប្រួល។

ការប្រែប្រួលទីផ្សារបណ្តាលមកពីការផ្ទុះជំងឺ និង ការឆ្លើយតបនូវគោលនយោបាយរបស់រដ្ឋាភិបាល ធ្វើឲ្យវាមានការលំបាកក្នុងការកំណត់សមាមាត្រផលិតកម្មសាច់ក្នុងស្រុក ប្រៀបធៀបទៅនឹងការនាំចូល ។ នៅឆ្នាំ ២០១០ ព័ត៌មានទីផ្សារមុននឹងមានការហាមឃាត់ការនាំចូល បានបង្ហាញថា ការនាំចូលជាផ្លូវការ គឺប្រហែល ២៩.២០០[២៣] តោននិងក្រៅផ្លូវការ និង៣៥.៥០០[២៤]តោន ។ ព័ត៌មានដែលគេផ្តល់ឲ្យនេះ វាអាចទាញយកមកធ្វើការប៉ាន់ស្មានពីផលិតកម្មក្នុងស្រុក ។ តែទោះជាយ៉ាងណាក៏ដោយ តាមតារាងដែលបង្ហាញខាងក្រោមនេះគឺងាយរងគ្រោះយ៉ាងខ្លាំងចំពោះការប៉ាន់ស្មានពី ការបរិភោគសាច់ក្នុងស្រុក ។

**ការប៉ាន់ស្មានពីការប្រើប្រាស់សាច់ជ្រូកសរុប(២០១០)**

| | ២លានក្បាល | | ១,៥លានក្បាល | |
|---|---|---|---|---|
| | តោន | | តោន | |
| ការនាំចូលផ្លូវការ | 29,200 | 15% | 29,200 | 20% |
| ការនាំចូលក្រៅផ្លូវការ | 36,500 | 18% | 36,500 | 25% |
| ផលិតកម្មក្នុងស្រុក | 134,300 | 67% | 80,300 | 55% |

ទោះបីក្នុងដំណាក់កាលនិមួយបង្ហាញយ៉ាងច្បាស់ពីការប្រែប្រួលយ៉ាងនេះក៏ដោយ ក៏ធ្វើឲ្យមានការបាក់ទឹកចិត្តដល់ការវិនិយោគទុនរយៈពេលវែងនៅក្នុងអាជីវកម្មចិញ្ចឹមជ្រូកនេះផងដែរ ។






**៤. ការលើកកម្ពស់បរិយាកាសអាជីវកម្ម**

យុទ្ធសាស្ត្ររបស់រដ្ឋាភិបាលដោះស្រាយដោយផ្ទាល់ការប្រែ ប្រួលទីផ្សារគឺតាមរយៈការត្រួតពិនិត្យយ៉ាងជិតដល់ពីការនាំចូល និងកំរិតបទដ្ឋាន សុខភាពសត្វ។ បន្ថែមពីនេះទៅទៀត រដ្ឋាភិបាលមានគោលដៅលើកកម្ពស់ផលិតភាពនៅក្នុងអាជីវកម្មជ្រូកក្នុងស្រុកតាមរយៈគោលនយោបាយវិនិយោគ សាធារណៈសំខាន់ៗ និងការលើកទឹកចិត្តដល់វិស័យឯកជនតាមរយៈការផ្តល់កំលាំងចិត្តវិនិយោគដែលគួរឲ្យចាប់អារម្មណ៍ ។

## គោលនយោបាយគាំទ្រ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ២០០៩ បានដាក់ចេញជាគោលនយោបាយដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម ចិញ្ចឹមជ្រូក ។ ចំនុចទាំងនេះដាក់បញ្ចូលគ្នាចេញជាគំនិតផ្តួចផ្តើមដើម្បីៈ

- លើកស្ទួយសុខភាពជ្រូកទូទៅ និងកាត់បន្ថយអត្រាងាប់
- លើកកម្ពស់គុណភាពផលិតកម្មសត្វ
- លើកទឹកចិត្តដល់ការវិនិយោគឧស្សាហកម្មចិញ្ចឹមសត្វ
- ផ្តល់ឥណទានសំរាប់កម្មវិធីឡជីវឧស្ម័ន

បច្ចុប្បន្នរដ្ឋាភិបាលកំពុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ឧបាស្រ័យពាណិជ្ជកម្មដើម្បីដោះស្រាយការលក់បង្ខូចថ្លៃ និងការរកស៊ីគ្មានការប្រកួតប្រជែងដទៃទៀត ។ សេចក្តីព្រាងច្បាប់នេះរំពឹងថា នឹងបញ្ចប់នៅដើមឆ្នាំ ២០១១ ។

## ការចាប់ផ្តើមលើកទឹកចិត្ត

**គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់(QIPs)** ទទួលបានការអនុម័តដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) ទទួលបាន ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុមួយចំនួន តែមិនកំណត់ រួមមាន ការលើកលែងពន្ធថ្លៃឈប់សំរាក និងការរួចពន្ធនាំចូលសំរាប់ឧបករណ៍ផលិត និងសំភារៈសំណង់ ។ QIPs មិនតម្រូវធ្វើការបង់ថ្លៃមុននូវពន្ធប្រាក់ចំណេញ និងការដាក់ពន្ធអប្បបរមានៅអំឡុងពេលការរួចពន្ធ ។

ទាំងនេះជាការយកចិត្តទុកដាក់លើការវិនិយោគផ្នែកអាជីវកម្មជ្រូកដែលនឹងទទួលផល ប្រយោជន៍យ៉ាងធំធេងដែលចេញពីការលើកទឹកចិត្តបែបនេះ។ ខាងក្រោមនេះ គឺជាចំនុចចាប់ផ្តើមសំរាប់ការដាក់ពាក្យសុំយកការអនុញ្ញាតិពី QIPs សំរាប់ទាំងអាជីវករផលិតចំណីសត្វ និងអាជីវករកាប់ជ្រូកៈ

- អាជីវករផលិតចំណីសត្វ: ការវិនិយោគចំនួនទឹកប្រាក់ ១០០.០០០ ដុល្លារ ឬលើសពីនេះ
- ការផលិតនូវផលិតផលចំណីអាហារ: ការវិនិយោគចំនួនទឹកប្រាក់ ៥០០.000 ដុល្លារ ឬលើសពីនេះ

គ្រប់ការវិនិយោគទុនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងអស់ អាចទទួលបានការរួចពន្ធការរួចពន្ធនាំចូលចំពោះឧបករណ៍ផលិតកម្មសំភារៈសំណង់ និងវត្ថុធាតុផលិតកម្មផ្សេងៗទៀត ។ អាជីវកម្មដែលមានលក្ខណៈសម្បត្តិ

QIPs នឹងទទួល បានសិទ្ធិរួចពន្ធនាំចេញ ១០០%។

ការវិនិយោគទុនក្រោមទឹកប្រាក់ ២លានដុល្លារ គឺត្រូវអនុម័តដោយខេត្ត ដោយមិនចាំបាច់មាន ការអនុម័តយល់ព្រមពី ក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជា(CDC) នៅភ្នំពេញឡើយ ។ ខេត្តនីមួយៗ មាន អនុគណៈកម្មាធិការវិនិយោគខេត្តសំរាប់ កិច្ចការនេះ ដែលមានអភិបាលខេត្តជាប្រធាន និងអ្នកតំណាងតំបន់ម្នាក់មកពី ក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា។ នៅតំបន់ណាដែលអនុគណៈ កម្មាធិការមិនទាន់មានដំណើរការពេញលេញទេ វិនិយោគិនទាក់ទងតាមរយៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជា នៅភ្នំពេញ ។

**តំបន់សេដ្ឋកិច្ចពិសេស(SEZs):** តំបន់សេដ្ឋកិច្ចពិសេស បានផ្តល់នូវលក្ខខ័ណ្ឌអនុគ្រោះពិសេស ចំពោះដំណើរការសាងសង់រោងចក្រ ដូចការ ការផលិតចំណីសត្វ ឬការកែច្នៃសាច់ជ្រូក ។ តំបន់សេដ្ឋកិច្ចពិសេស នេះគឺជិតកន្លែងប្រជាជន រស់ច្រើនកកកុញ ហើយវិនិយោគិននឹងបាន ទទួលផលពីហេដ្ឋារចនាសម្ព័ន្ធដែលគុណភាព ខ្ពស់ សេវា ទឹក ភ្លើងថោក និងផលិតផលងាយ ចូលទៅកាន់ទីផ្សារ ។

**តំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជាអនុម័តយល់ព្រមដោយខេត្ត[២៥]**




រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តតំបន់សេដ្ឋកិច្ចពិសេស មានចំនួន២១តំបន់។ តំបន់៦កំពុង ដំណើរការ និងនៅសល់១៥តំបន់ផ្សេងទៀត សង្ឃឹមថានឹងមានសកម្មភាពនៅឆ្នាំ២០១៥[២៦] ។

ក្រៅពីមានហេដ្ឋារចនាសម្ព័ន្ធ វិនិយោគិន នៅ ក្នុងតំបន់សេដ្ឋកិច្ចពិសេស ទទួលបានការរួចពន្ធ លើតំលៃបន្ថែម (VAT) លើផលិតផលនិង សំភារៈនាំចូលនានា និងទទួលបានសេវាកម្មច្រក ចូលតែមួយពីខាងរដ្ឋាភិបាល:

| ច្រកចេញចូលតែមួយ | ហេដ្ឋារចនាសម្ព័ន្ធមានគុណភាព |
| --- | --- |
| ការចុះបញ្ជីវិនិយោគទុន<br>លិខិតអនុញ្ញាតនាំចូល/នាំចេញ<br>ទូទាត់បញ្ជីគយ<br>ការចាត់ចែងកម្លាំងពលកម្ម | អគ្គិសនី<br>ទឹកស្អាត<br>មានសេវាអ៊ិនធឺណេត<br>ដែលទុកចិត្តបាន |

អាជីវកម្មនៅក្នុង តំបន់សេដ្ឋកិច្ចពិសេស ទទួលផលពីការលើកទឹកចិត្តសារពើពន្ធមួយចំនួនផង ដែរ រួមទាំងពន្ធលើប្រាក់ចំណូល ពន្ធគយ និង ផលប្រយោជន៍ពន្ធលើតម្លៃបន្ថែម ។

## សេវាហិរញ្ញវត្ថុ

កម្ពុជាកំពុងតែមានការរីកចំរើនខាងផ្នែកហិរញ្ញវត្ថុ រួមមានធនាគារ៣៣ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ២០ ដែលផ្តល់អាជ្ញាប័ណ្ណដោយ ធនាគារជាតិនៃ កម្ពុជា ។ ស្ថាប័នសរុបរួមទាំងអស់នបានផ្តល់ ប្រាក់កម្ចីជាង ៣០០លានដុល្លារអាមេរិក សំរាប់ វិស័យកសិកម្ម និងគោលបំណងផ្សេងៗហើយជា លទ្ធផលប្រហែល១០%នៃឥណទានសរុបដែល គេផ្តល់ឲ។ ធនាគារតាមអ៊ិនធឺណេត ធនាគារ ចល័ត និង ATMs ជាទូទៅមាននៅក្នុងតំបន់ទីក្រុង និងទីប្រជុំខេត្ត ។
ដើម្បីជំរុញគុណភាពក្នុងវិស័យនេះ ធនាគារជាតិ



នៃកម្ពុជា បានតម្រូវឲ្យ ធនាគារពាណិជ្ជកម្មនីមួយ ៗបង្កើនដើមទុនតម្កល់គុណនឹងបីដង ប្រហែល៣៧លានដុល្លារអាមេរិក ហើយចាប់មានប្រសិទ្ធភាពនៅចុងឆ្នាំ ២០១០តទៅ ។

## ៥. ការធ្វើពាណិជ្ជកម្ម

ក្នុងនាមជាសមាជិកម្នាក់នៃ អង្គការពាណិជ្ជកម្មពិភពលោក(WTO) និងសមាជិកប្រជាជាតិអាស៊ីអាគ្នេយ៍(ASEAN) កម្ពុជាបានទទួលទីផ្សារទាំងក្នុងតំបន់ និងទីផ្សារអន្តរជាតិ ។ កម្ពុជាបានទទួលផលប្រយោជន៍ផងដែរពីអត្រាពន្ធគយនាំចូលទាប ដែលបង្ហាញនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ីអាគ្នេយ៍ (AFTA) ។

**អត្រាពន្ធគយនាំចូល AFTA របស់កម្ពុជា[២៨]**

| បរិយាយ | អត្រាពន្ធអនុវត្ត ដោយ AFTA |
|---|---|
| *ជ្រូកពូជសុទ្ធ (HSC Code 0101310) | ៧% |
| * ជ្រូករស់ពូជសុទ្ធ ទំងន់ < ៥០គក មិនរាប់ចូលពូជសុទ្ធបង្កាត់ (HSC Code 010391) | ៧% |
| * ជ្រូករស់ពូជសុទ្ធ ទំងន់ >=៥០គក មិនរាប់ចូលពូជសុទ្ធបង្កាត់ (HSC Code 010392) | ៧% |

## ៦. ការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធ

### ការវិនិយោគផ្នែកសាធារណៈ:

ដោយសហការជាមួយនឹងប្រទេសចិន រដ្ឋាភិបាលកម្ពុជា បានបង្កើតនូវគម្រោងបង្កាត់ពូជជ្រូកកម្ពុជាស៊ីណូដើម្បីកែលំអរពូជជ្រូកដែលកសិករបានយកមកសំរាប់ចិញ្ចឹម ។ ផ្អែកតាម ស្ថានីយ៍បង្កាត់ពូជជ្រូករបស់រដ្ឋាភិបាល គម្រោងការ នេះមានគោលដៅដើម្បីបង្កើនបរិមាណសាច់



ក្រហមឲបានច្រើនដល់អាជីវករចិញ្ចឹមជ្រូកក្នុងប្រទេសកម្ពុជាដោយថែរក្សាកូនជ្រូកទាំងនោះសំរាប់ទុកធ្វើពូជ។

កម្ពុជា មាន វិទ្យាស្ថានស្រាវជ្រាវបសុព្យាបាលជាតិ (NaVRI) ផងដែរដែលដើរតួយ៉ាងសំខាន់នៅក្នុងការធ្វើរោគវិនិច្ឆ័យ ស្រាវជ្រាវ និងការត្រួតពិនិត្យជំងឺសត្វ ។

### ការដឹកជញ្ជូន

ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនសខាន់ៗបានជួយលើកកម្ពស់នូវការចែកចាយផលិតផលទូទាំងប្រ ទេស និងសក្តានុពលនាំចេញ ដែលផ្តល់លទ្ធភាពដល់អាជីវករនៅកម្ពុជាស្រូបយកការផ្គត់ផ្គង់ ខ្សែសង្វាក់ក្នុងស្រុក និងពិភពលោក ។

### ផ្លូវថ្នល់:

គេអាចចូលមកកាន់ទីក្រុងភ្នំពេញបានតាមរយៈផ្លូវថ្នល់ជាតិដែលកសាងយ៉ាងល្អតភ្ជាប់ជាមួយនឹងបណ្តាលខេត្តទាំងអស់[២៩] ។
នៅទូទាំងប្រទេស មានច្រកព្រំដែនអន្តរជាតិចំនួន៧ ដែលមានផ្លូវចេញចូលដោយគ្មានការរអាក់រអួលទៅប្រទេសជិតខាង ថៃ ឡាវ វៀតណាម ។

**ទន្លេ:** ជារឿយៗ ទន្លេមេគង្គត្រូវបានគេប្រើដើម្បីដឹកជញ្ជូនទំនិញសំរាប់ធ្វើពាណិជកម្ម (ភាគច្រើនជាផលិតផលកសិកម្ម) និងបានតភ្ជាប់ពីកម្ពុជាទៅប្រទេសឡាវ និងវៀតណាម។

**ផ្លូវដែក:** រាជរដ្ឋាភិបាលកម្ពុជា កំពុងសហការជាមួយ នឹងធនាគារអភិវឌ្ឍន៍អាស៊ី(ADB)និងដៃគូម្ចាស់ជំនួយនានាដើម្បីស្តារឡើងវិញនូវបណ្តាញ

ខ្សែរថភ្លើងថ្នាក់ជាតិ។ ផ្លូវដែកចំនួនពីរខ្សែ សំខាន់ៗ រត់កាត់ពី ប៉ោយ ប៉ែត (នៅតាមព្រំដែនភាគខាងលិច ជាប់ជាមួយនឹងប្រទេសថៃ) មក ភ្នំពេញ និងមួយខ្សែទៀត តភ្ជាប់ពី កំពង់ផែព្រះសីហនុ មក សំរោង រត់កាត់តាមព្រំដែនភាគខាងត្បូងជាប់ជាមួយនឹងប្រទេសវៀតណាម។ គម្រោងនៃការស្តារឡើងវិញ ផ្លូវដែក ទាំងពីរខ្សែនេះនឹងត្រូវបញ្ចប់នៅឆ្នាំ ២០១៣[៣០] ។

## កាលានុវត្តន៍ភាព(ឱកាស)សំរាប់ធ្វើអាជីវកម្ម

ស្ថានភាពការចិញ្ចឹមជ្រូកបច្ចុប្បន្ននៅកម្ពុជាផ្តល់ផលប្រយោជន៍ជាច្រើនក្នុងការវិនិយោគអាជីវកម្មផ្សេងៗ និងបង្កើនដើមទុនឲកាន់តែរីកចម្រើនតាមតម្រូវការក្នុងស្រុក និង ក្រៅប្រទេស ។

**ការផលិតចំណីសត្វ:** កម្ពុជាសំបូរវត្ថុធាតុដើមជាច្រើនសំរាប់ផលិតចំណីសត្វ ហើយកំរមានអាជីវ-ករក្នុងស្រុកនាំវត្ថុធាតុដើមទាំងនេះចេញណាស់ នៅពេលតំលៃក្នុងស្រុកទាបវានឹងផ្តល់សារៈប្រយោជន៍ដល់ការទាក់ទាញវិនិយោគទុន។ ការកែច្នៃចំណីសត្វដែលមានទីតាំងនៅប្រទេសកម្ពុជាផ្តល់សក្តានុពលភាពដ៏ធំធេងដើម្បីស្រូបយកតម្រូវការក្នុងស្រុក ក៏ដូចជាតម្រូវការក្រៅប្រទេសផងដែរ។

**ការកែច្នៃ:**

ផលិតផលសាច់ជ្រូកកែច្នៃបានតម្លៃបន្ថែម បង្កើនទិន្នផល និងជួយថែរក្សាទុកផលិតផលបានយូរ ហើយអាចមានលទ្ធភាពបែងចែកនិងនាំចេញឲកាន់តែទូលំទូលាយ ។

ផលិតផលកែច្នៃអាចជួយជំរុញឲផលិតផលដែលមានស្លាកយីហោ កាន់តែមានសក្តានុពលខ្លាំងថែមទៀត។ បច្ចុប្បន្ន កម្ពុជាបាន នាំចូលផលិតផលកែច្នៃយ៉ាងច្រើនក្នុងទីផ្សារ ទោះបីមានការកែច្នៃបែបសិប្បកម្មទ្រង់ទ្រាយតូចខ្លះៗនៅក្នុងទីក្រុងភ្នំពេញក៏ដោយ ។

**ការនាំចេញផលិតផលសាច់ជ្រូក**

បើយើងពិចារណា លើសាច់ជ្រូក និងផលិតផលកែច្នៃ ប្រភេទតម្លៃទីផ្សារនាំចេញជាច្រើនហាក់ដូចជាមានតំលៃខ្ពស់ នេះឆ្លុះបញ្ចាំង ពីផលិត-ផលមានគុណភាពល្អ រសជាតិឆ្ងាញ់ និងផលិត-ផលចំរុះគ្នា ដទៃទៀត ។ លើសពីនេះទៀតទីផ្សារនាំចេញមិនប៉ះពាល់ពីតម្រូវការរយៈពេលខ្លីនៃទីផ្សារក្នុងស្រុក របស់កម្ពុជាទេ ។

**ផលិតកម្មចំរុះ**ក្រុមហ៊ុនដែលមានផលិតកម្ម ចំរុះរួមមានបង្កាត់ពូជរហូតដល់ការកែច្នៃ គប្បីទទួលបាននូវការសន្សំថ្លៃដើម និងផលប្រយោជន៍ ពីការគ្រប់គ្រងគុណភាពប្រកបដោយ ប្រសិទ្ធភាព ។ ក្រុមហ៊ុនជាច្រើនកំពុងតែអនុវត្តរួចហើយ នូវគំរូនេះ តែទោះបីជាយ៉ាងណាក៏ដោយ ពួកគេអាច តំណាងបានតែមួយភាគតូចនៃផលិតកម្មទាំងមូលប៉ុណ្ណោះ ។ នេះបង្ហាញឲ្យឃើញថា នៅមាន កាលានុវត្តន៍យ៉ាងធំ ក្នុងការបង្កើនដើមទុននៅ លើអាជីវកម្មនេះ ។

**មាត្រដ្ឋានសេដ្ឋកិច្ច:**

កម្ពុជាកង្វះនូវអ្នកផលិតដែលមានសមត្ថភាពសំរាប់វិនិយោគលើការផលិតនិងបច្ចេកទេសសន្សំ លើការចំណាយ ដូចជា ការកែច្នៃឡជីវឧស្ម័ន សំរាប់យកមកប្រើជាថាមពលនិងជី។ តែទោះបីយ៉ាងណាក៏ ដោយ ទាំងនេះគឺជាកាលា-នុវត្តន៍ភាពបន្ថែមទៀតសំរាប់អ្នកផលិតខ្នាតធំ ។

**ហិរញ្ញប្បទានកាបូន:** ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍(LDC) កម្ពុជាគឺមានទីកន្លែងល្អ ដើម្បីទទួលបានផលពីគម្រោងការដែលរៀបចំ សំរាប់ផ្តល់ហិរញ្ញវត្ថុដល់គម្រោងដែលកាត់បន្ថយ ការបំភាយឧស្ម័នផ្ទះកញ្ចក់ ។

ក្រោមគម្រោងការបែបនេះ ជាឧទាហរណ៍ តាមការប្រើនូវយន្តការអភិវឌ្ឍន៍ស្អាត(CDM) តំលៃកាកសំណល់ចេញពីឡ អាចទទួលការ



ផ្តល់ហិរញ្ញប្បទានតាមរយៈការលក់ឥណទានកាបូន ។

**ស្លាកយីហោ:** និយាយជារួម ដើមកំណើតនៃសាច់ជ្រូកលក់នៅកម្ពុជាគឺមិនអាចកំណត់បានទេ ដូច្នេះហើយ ការភ័យខ្លាចខាងសុខភាពនឹងបង្កឲ្យមានតម្រូវការធ្លាក់ចុះ។ តែទោះបីយ៉ាងណាក៏ដោយ ស្លាកយីហោដែលគេជឿទុកចិត្តនឹងទទួលបានផលប្រយោជន៍ពីការចង់ទិញពីអ្នកប្រើប្រាស់ ។

**សេវាបសុពេទ្យ:**
ក្រុមហ៊ុនដែលមានសេវាបសុព្យាបាលចំនួនតិចតួច កំពុងប្រតិបត្តិការនៅកម្ពុជា ដែលមានម្ចាស់ជាជនជាតិខ្មែរ ។ តែទោះបីជា យ៉ាងណាក៏ដោយ ការទទួលបានការប្រើប្រាស់ថ្នាំនិងសេវាបសុព្យាបាល ដែលមានគុណភាពនៅតែ ជាឧបសគ្គចម្បងដល់អាជីវករចិញ្ចឹមជាលក្ខណៈគ្រួសារ និងអាជីវករចិញ្ចឹមជាពាណិជ្ជកម្មខ្នាតតូចនៅឡើយទេ ។

**សេវារក្សាស្តុកផលិតផល** បច្ចុប្បន្នមានអ្នកផលិតសាច់ជ្រូកនិងអ្នកចែកចាយសាច់ជ្រូកជាច្រើនត្រូវការថែរក្សាសាច់ក្នុងធុងទឹកកក(ក្លាសេ)។ ការក្សាបែបនេះអាចមានសមត្ថភាពដឹកជញ្ជូន

ផលិតផលបានឆ្ងាយនិងមានលទ្ធភាពទាក់ទាញអតិថិជនបានកាន់តែច្រើន និងអាចពង្រីកទីផ្សារបានកាន់តែទូលំទូលាយ ។

## ដៃគូអភិវឌ្ឍន៍នៅក្នុងអាជីវកម្មជ្រូក

ដៃគូអភិវឌ្ឍន៍មួយចំនួនកំពុងជួយអភិវឌ្ឍន៍ដល់វិស័យឯកជនផ្នែកអាជីវកម្មជ្រូក:



**គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និង ខ្នាតមធ្យមកម្ពុជា(MSME)** ឧបត្ថម្ភដោយ **USAID** បានសម្របសម្រួលផ្តល់ជំនួយខាងបច្ចេកទេស និងការធ្វើអាជីវកម្មដល់សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមរាប់ពាន់នៅតាមជនបទក្នុងប្រទេសកម្ពុជា ។សកម្មភាពថ្មីៗរបស់គម្រោងMSME ផ្នែកជ្រូក បានដាក់បញ្ចូលនូវសកម្មភាពដើម្បីលើកកម្ពស់ផលិតកម្មអាជីវកម្មខ្នាតតូច ជំរុញឲមានការប្រកួតប្រជែង និងការរៀបចំកិច្ចពិភាក្សា រវាងវិស័យឯកជន ជាមួយនឹងសារធារណៈ ។

គម្រោងMSME បានផ្តោតការយកចិត្តទុកដាក់ទៅលើការសម្របសម្រួលបច្ចេកទេសចំនួន ៨ផ្នែក ផ្សេងទៀត រួមមាន: វារីវប្បកម្ម ឡឥដ្ឋ-ក្បឿង ទឹកស្អាត និងបង្គន់អនាម័យ ការអភិវឌ្ឍន៍ជំនាញដល់ឧស្សាហកម្មកាត់ដេរ ទឹកឃ្មុំ ជ័រទឹក និងទេសចរណ៍ធម្មជាតិ ។

**គម្រោងអភិវឌ្ឍន៍កសិពាណិជ្ជកម្ពុជា**(CADF) គឺជាគម្រោងអភិវឌ្ឍន៍កសិពាណិជ្ជ ដែលផ្តល់មូលនិធិដោយNZAID ដែល មានគោលបំណងលើកកម្ពស់ខ្សែសង្វាក់អាជីវកម្មកសិកម្មនានាមានដូចជា ជ្រូក បន្លែ ផ្លែឈើ ផ្សិត និងសូត្រ ។ នៅក្នុងវិស័យជ្រូក គម្រោងនេះបានជួយដល់អាជីវករចិញ្ចឹមជ្រូកនៅខេត្តសៀម រាប និងបន្ទាយមានជ័យ តាមរយៈការលើកកម្ពស់ការកែច្នៃចំណីសត្វ ការថែទាំសុខភាព និងគុណភាពពូជ ។

អង្គការស្បៀងអាហារនិងកសិកម្ម(FAO)បានជួយ ដល់អាជីវកម្មជ្រូកដោយធ្វើការជួយគាំទ្រខាងការធ្វើរោគវិនិច្ឆ័យ និងការគ្រប់គ្រងជំងឺជ្រូក

ដោយមានគោលដៅលើកកម្ពស់សុខភាពជ្រូក និងការលំអរផលិតកម្ម ។

Celagrid គឺជាអង្គការមិនមែនរដ្ឋាភិបាល ដែលជួយឧបត្ថម្ភគាំទ្រដល់សហគមន៍ចំនួន៤០០ នៅខេត្ត តាកែវ ពោធិ៍សាត់ និងកណ្តាល ដោយផ្តល់ប្រឹក្សាខាងបច្ចេកទេសអំពីការចិញ្ចឹមជ្រូក ការផលិតចំណីសត្វ និងឡជីវឧស្ម័ន ។

**នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល** គឺជាសេនាធិការរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាន វិទ្យាស្ថានជាតិស្រាវជ្រាវខាងបសុព្យាបាល វិទ្យា ស្ថានជាតិស្រាវជ្រាវផលិតកម្មសត្វ(កំពុងដំណើរការបង្កើត) និងការិយាល័យនៅទូទាំង២៤ខេត្ត ក្រុង ។ ការងាររបស់គេ រួមមាន ការសិក្សាអំពីបច្ចេកទេសចិញ្ចឹមសត្វ ពូជ សេនេទិច និងចំណីសត្វ និងការងារផ្សព្វផ្សាយបច្ចេកទេសដើម្បីលើក កម្ពស់ផលិតភាព ។ វិទ្យាស្ថានជាតិស្រាវជ្រាវខាងបសុព្យាបាល ទទួលខុសត្រូវលើការធ្វើរោគវិនិច្ឆ័យស្រាវជ្រាវ និងត្រួតពិនិត្យជំងឺ ។

**នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល** ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតគោលនយោបាយដែលគោរពទៅតាមគោលការណ៍សុខភាពសត្វ និងផលិតកម្ម ។

## ព្រឹត្តិការណ៍ថ្មីៗ

**២០០៨**: ការបង្កើតកិច្ចសហការចិញ្ចឹមជ្រូក រវាងក្រុមហ៊ុន ម៉ុង រិទ្ធី គ្រុប ជាមួយនឹង ក្រុមហ៊ុន ACMC ដែលជាក្រុមហ៊ុនបង្កាត់ពូជ និងសេនេទិចជ្រូកមួយនៅអង់គ្លេស ។ ក្រុមហ៊ុននេះមានជ្រូកសំរាប់ទុកធ្វើពូជជ្រូកសាច់ ផលិតចំណីសត្វ និងកែច្នៃសាច់ជ្រូក ហើយមានគោលដៅដើម្បីផ្តល់ការផ្គត់ផ្គង់ជ្រូកដល់សត្តឃាតដ្ឋាន ១,១លានក្បាលក្នុងមួយឆ្នាំចាប់ពីឆ្នាំ ២០១៥ ។

**២០០៩**: ក្រុមហ៊ុនវិនិយោគកូរ៉េ (KOGID) ប្រកាសពី គម្រោងផែនការវិនិយោគទុនចំនួន ១៥០លានដុល្លារ អាមេរិកលើការកែច្នៃគ្រាប់ធញ្ញជាតិសំរាប់ផលិតចំណីសត្វ ។

**២០១០**: ធនាគារអាល្លឺម៉ង់ KfW Bankengruppe ប្រើប្រាស់ឥណទានកាបូនដើម្បីហិរញ្ញប្បទានដល់រោង ចក្រផលិតអគ្គិសនីមួយនៅកសិដ្ឋានចិញ្ចឹមជ្រូកចំនួន៥០០០ក្បាលខេត្ត ព្រះសីហនុ ។

**ខែឧសភា ២០១០**: ក្រុមហ៊ុនកម្ពុជា BVB Investments ប្រកាសពីគម្រោងផែនការវិនិយោគទុនចំនួន១៩លានដុល្លារ ដែលរួមមាន កសិដ្ឋានចិញ្ចឹមជ្រូក សត្តឃាតដ្ឋាន និងរោងចក្រកែច្នៃសាច់នៅក្នុងខេត្តកំពង់ធំ ។

**ខែសីហា ២០១០**: រាជរដ្ឋាភិបាលកម្ពុជា បានដាក់ បំរាមជាបណ្តោះអាសន្នលើការនាំជ្រូកចូលពីប្រទេស វៀតណាម និងថៃ ដោយទាក់ទងទៅនឹងការផ្ទុះជំងឺ ។





**តើអ្នកចង់ស្វែងយល់បន្ថែមទៀតទេ**?

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)

www.cambodiainvestment.gov.kh

សភាពាណិជ្ជកម្មកម្ពុជា

www.ccc.org.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

(រួមទាំង នាយកដ្ឋានផលិតកម្ម និងបសុពេទ្យាបាល)

www.maff.gov.kh

វិទ្យាស្ថាន ស្ថិតិជាតិ

www.nis.gov.kh

គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមកម្ពុជា (MSME)

www.cambodiamsme.org

អង្គការស្បៀងអាហារ និងកសិកម្ម **(FAO)**

www.fao.org

**ស្ថិតិគន្លឹះ**

## ស្ថិតិជ្រូក (២០០៩)[១]

| | |
|---|---|
| ស្តុកជ្រូក | ២.១២៦.៣០៤ក្បាល |
| បរិភោគក្នុងម្នាក់ | ៩.២៩ |
| %ចិញ្ចឹមជាលក្ខណ:គ្រួសារ | ៩០% |
| %ចិញ្ចឹមបែបពាណិជ្ជកម្ម | ១០% |
| ផលិតកម្ម(២០០៧) | ១១០.០០០តោន |
| សាច់ជ្រូករស់(តំលៃផលិត) | $៤.៤៤៦/តោន |
| សាច់ជ្រូក (តំលៃផលិត) | $៦.៤៤៤/តោន |
| ចំនួនស្តុករួមចំណែកដល់ GDP | ៥% |

## ស្ថានភាពនៅកម្ពុជា[២]

| | |
|---|---|
| ទំហំផ្ទៃក្រឡា | ១៨១.០៣៥គម$^{២}$ |
| អាកាសធាតុ | ត្រូពិច |
| សីតុណ្ហភាពជាមធ្យម | ២៧$^{0}$C ឬ ៨0F |
| ចំនួនប្រជាជន | ១៣.៣៩៥.៦៨២(២០០៨) |
| អត្រាកំណើនប្រ/ជប្រចាំឆ្នាំ | ១,៥៤% |
| ភាសាផ្លូវការ | ខ្មែរ |
| ភាសាពាណិជ្ជកម្ម | ខ្មែរ និងអង់គ្លេស |
| សាសនា | ព្រះពុទ្ធ |
| ឆ្នេរសមុទ្រ | ៤៤០គម |

## អត្រាពន្ធកម្ពុជា

| | | |
|---|---|---|
| ពន្ធលើប្រាក់ចំណេញ | ធម្មតា | ២០% |
| | លើកទឹកចិត្ត | 0% ឬ ៩% |
| ពន្ធអប្បបរមា | | ១%នៃផលរបរ |
| ពន្ធកាត់ទុក | | ១៥% |
| ប្រាក់ចំណូលពីការជួលអចលនវត្ថុ | | ១០% |
| ការបង់ប្រាក់ឲ្យអនិវាសនជន | | ១៤% |
| ពន្ធលើប្រាក់បៀវត្សរ៍(រៀលក្នុងមួយខែ) | | |
| 0 - ៥០០.000 | | 0% |
| ៥០០.00១-១.២៥០.000 | | ៥% |
| ១.២៥០.000 - ៨.៥០០.000 | | ១០% |
| ៨.៥០០.00១ - ១២.៥០០.000 | | ១៥% |
| ១២.៥០០.000+ | | ២០% |
| អនិវាសនជន | អត្រាថេរ | ២០% |
| ពន្ធបន្ថែមលើផលបន្ទាប់បន្សំ | | ២០% |
| ពន្ធបន្ថែមលើតំលៃ | | ១០% |
| | នាំចេញ | 0% |
| ពន្ធការផ្ទេរសិទ្ធិលើអចលនវត្ថុ | | ៤% |

## ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចកម្ពុជា[៤]

| កំណើន GDP(%) | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|---|
| កំណើននាំចេញ | ១៣.៣ | ១០.8 | ១០.២ | ៦.៧ | -២ | ៤.៤ |
| លើទំនិញតែប៉ុណ្ណោះ | ១២.៤ | ២៦.៩ | ១០.៧ | ១៥.២ | -១៧ | ៥ |
| %នាំចេញលើតែទំនិញ | ៤៧% | ៥០% | ៤៧% | ៤៦% | ៣៩% | 0.៣៧ |
| វិនិយោគផ្ទាល់ពីបរទេស(FDI)លានដុល្លារ | ៣៧៥ | ៤៧៥ | ៨៦៦ | ៧៩៦ | ៥១៥ | ៧២៥ |
| FDI (% of GDP) | ៦% | ៦% | ១០% | ៨% | ៥% | 0.0៧ |

## ការចំណាយអាជីវកម្ម[៥]

| ដី | តំលៃលក់(គិតជាម$^{២}$) |
|---|---|
| ភ្នំពេញ ដីពាណិជ្ជកម្ម | ៨០០-៥០០០ដុល្លារ |
| សៀមរាប ដីពាណិជ្ជកម្ម | ៣០០-៥០០ ដុល្លារ |
| ខេត្តព្រះសីហានុ ដីពាណិជ្ជកម្ម | ៣០០-១០០០ដុល្លារ |
| ដីអភិវឌ្ឍន៍ (គ្រប់ខេត្ត/ក្រុង) | ៣០-១២០ ដុល្លារ |

| កន្លែងការិយាល័យ | ជួល/ខែ (គិតជាម$^{២}$) |
|---|---|
| តំបន់ល្អ | ១០-១៥ ដុល្លារ |
| តំបន់លំដាប់ទី២ | ៧-១០ ដុល្លារ |

| ពន្ធគយលើអគ្គិសនីនៅភ្នំពេញ ពាណិជ្ជកម្ម និងឧស្សាហកម្ម | ពន្ធគយ ដុល្លារ/kWh (មធ្យមភាគ ២០០៩) |
|---|---|
| តូច (<៦.៧៥០kWh) | 0,១៨៦៣ ដុល្លារ |
| មធ្យម( ≥៦.៧៥០kWh តែតិចជាង១៣.៥០០kWh) | 0,១៧៨៣ដុល្លារ |
| ធំ ( ≥១៣.៥០០kWh) | 0,១៧៤២ដុល្លារ |
| ភ្ជាប់ផ្ទាល់ទៅនឹង MV | 0,១៧០៣ដុល្លារ |

ការផ្គត់ផ្គង់ឧស្សាហកម្មឧស្ម័ន 0,៣២ដុល្លារ/គក

| តំលៃពលកម្ម | ប្រាក់ខែ(មួយខែ) |
|---|---|
| អ្នកគ្រប់គ្រងជាន់ខ្ពស់ | ១០០០-១៥០០ដុល្លារ |
| អ្នកគ្រប់គ្រងថ្នាក់កណ្តាល | ៥០០-១០០០ដុល្លារ |
| អ្នកគ្រប់គ្រងថ្នាក់ក្រោម | ២៥០-៤០០ ដុល្លារ |
| គណនេយ្យករ | ២៥០-៤០០ ដុល្លារ |
| លេខាធិការ | ១២០-១៥០ ដុល្លារ |
| ស្មៀនការិយាល័យ | ១០០-១២០ ដុល្លារ |
| អ្នកបើកបរ | ១០០-១២០ ដុល្លារ |
| អ្នកសំអាត | ៥០-៨០ ដុល្លារ |
| កម្មករ | ៥០-៨០ ដុល្លារ |
| ប្រាក់ឈ្នួលអប្បបរមាសំរាប់កម្មកររោងចក្រកាត់ដេរ | ៦០ ដុល្លារ |